ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## មាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ២នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**២នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ម.ស.ណ** អាយុ៤៣ឆ្នាំ មកពីស្រុកត្រាំកក់ ខេត្តតាកែវ បានទៅម៉ាឡេស៊ីដោយធ្វើដំណើរតាមរថយន្តកាត់តាមប្រទេសថៃ ហើយបានធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក និងចង់ត្រឡប់មកផ្ទះវិញ ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ស្នើសុំជួយអោយបានត្រឡប់មកកម្ពុជាវិញ។

(២) ពលការិនី **អ.ស.ម** អាយុ៣០ឆ្នាំ មកពីស្រុកកងមាស ខេត្តកំពង់ចាម បានទៅម៉ាឡេស៊ីដោយធ្វើដំណើរតាមរថយន្តកាត់តាមប្រទេសថៃ ហើយបានធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយសារនឹករលឹកកូនរបស់ខ្លួន ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ស្នើសុំជួយអោយបានត្រឡប់មកកម្ពុជាវិញ។

ស្ថានទូតបានចេញលិខិតធ្វើដំណើរ សម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ ដល់ពលការិនីទាំងពីរអំឡុងពេលរង់ចាំមកកម្ពុជា។

ពលការិនី **ម.ស.ណ** ពលការិនី**អ.ស.ម** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៩ ខែមករា** ឆ្នាំ**២០១៧** វេលាម៉ោង**១៧:៣០** នាទី តាមជើងយន្តហោះ MH762 ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ